**ប្រការ ៤ :**

ក្នុងការបំពេញកិច្ចការនេះ ឯកឧត្តម **គាត ឈន់** ប្រើប្រាស់រចនាសម្ព័ន្ធរបស់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា (គអក/គជនា) ដែលមានឯកឧត្តម **ឈឿង យ៉ាណារ៉ា** ជាអគ្គលេខាធិការសំរាប់ជំនួយការងារប្រចាំថ្ងៃ ។

**ប្រការ ៥ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងឯកឧត្តម **គាត ឈន់** ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ ៦ :**

សេចក្តីសំរេចនេះ មានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខារហូតដល់កិច្ចប្រជុំលើកទី ៥ នៃក្រុមពិគ្រោះយោបល់បានប្រព្រឹត្តទៅចប់សព្វគ្រប់ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

***

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែមករា ឆ្នាំ ២០០១

## សេចក្តីសំរេចលេខ ០៣ សសរ.

## ស្តីពី

## ការបង្កើតគណៈកម្មការចំរុះអន្តរក្រសួង ដោះស្រាយបញ្ហារថយន្តចង្កូតសាំ

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

www.pheakdeylaw.com

-យោងតាមស្មារតីអង្គប្រជុំអន្តរក្រសួងនាថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។

**សំរេច**

**ប្រការ ១ :**

បង្កើតគណៈកម្មការចំរុះអន្តរក្រសួង ដើម្បីដោះស្រាយបញ្ហារថយន្តចង្កូតស្តាំ ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម **ឃី តាំងលីម** | រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រធាន |
| ២- ឯកឧត្តម **ឯម សំអាន** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣- ឯកឧត្តម **អ៊ុក រ៉ាប៊ុន** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៤- ឯកឧត្តម **ប៉ែន ស៊ីម៉ន** | ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកនាយកទីចាត់ការគយ និងរដ្ឋាករ | ជាសមាជិក |
| ៥- ឯកឧត្តម **ឡាយ អ៊ីពិសិដ្ឋិ** | អនុរដ្ឋលេខាធិការក្រសួងការពារជាតិ | ជាសមាជិក |
| ៦- ឯកឧត្តម **តេង ឈុន** | មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស | ជាសមាជិក |
| ៧- ឯកឧត្តម **តេង សាវង្ស** | អគ្គនាយករងនគរបាលជាតិ | ជាសមាជិក |
| ៨- ឯកឧត្តម **ឡាយ រិទ្ធី** | នាយករងទីចាត់ការគយ និងរដ្ឋាករ | ជាសមាជិក |
| ៩- ឯកឧត្តម **ឡេង ធនយុទ្ធា** | អគ្គនាយកនៃអគ្គនាយកដ្ឋានដឹកជញ្ជូន | ជាលេខាអចិន្ត្រៃយ៍ |

**ប្រការ ២ :** គណៈកម្មការចំរុះអន្តរក្រសួងមានភារកិច្ច :

-ត្រួតពិនិត្យក្រុមហ៊ុនកែចង្កូតរថយន្ត អោយអនុវត្តបានត្រឹមត្រូវតាមនិយាមបច្ចេកទេស ។

-ត្រួតពិនិត្យផ្លាកលេខ និងប័ណ្ណសំគាល់រថយន្តចង្កូតស្តាំ ស្រង់ស្ថិតិរថយន្តចង្កូតស្តាំទាំងអស់ដែលកំពុងធ្វើចរាចរនៅលើផ្លូវសាធារណៈ ។

-ត្រួតពិនិត្យគុណភាពរថយន្ត ឆ្នាំផលិត កាលបរិច្ឆេទនៃការនាំចូល រួចហើយធ្វើការបែងចែកជាជំពូករថយន្តនាំចូលចាប់ពីមុនការប្រកាសហាមឃាត់ មកដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥ និងជំពូករថយន្តនាំចូលក្នុងចន្លោះពីថ្ងៃទី០១ ខែសីហា ឆ្នាំ១៩៩៥ មកដល់ថ្ងៃទី០១ ខែឧសភា ឆ្នាំ១៩៩៩ ។

www.pheakdeylaw.com

-រាយការណ៍លទ្ធផលការងារជូនរាជរដ្ឋាភិបាល និងលើកយោបល់លើករណីនីមួយៗជូនរាជរដ្ឋាភិបាលពិនិត្យ និងដោះស្រាយ ។

-បំពេញភារកិច្ចផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលប្រគល់អោយ ។

**ប្រការ ៣ :**

គណៈកម្មការចំរុះអន្តរក្រសួង មានសិទ្ធិបង្កើតអនុគណៈកម្មការ ដើម្បីជាជំនួយការក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន ទៅតាមការចាំបាច់ជាក់ស្តែង ។ សមាសភាពអនុគណៈកម្មការ ត្រូវជ្រើសរើសចេញពីមន្ត្រីជំនាញនៃក្រសួងពាក់ព័ន្ធ ។

**ប្រការ ៤ :**

សមាជិកគ្រប់រូបរបស់គណៈកម្មការចំរុះអន្តរក្រសួង ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។ គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ។

**ប្រការ ៥ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងសាមីខ្លួន ត្រូវសហការអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

====

## II- ការងារបណ្តាក្រសួង

### ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

### ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែមករា ឆ្នាំ២០០១

**ប្រកាសលេខ ០១៨ ឧរថគឧ.ប្រក.**

---

### រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

www.pheakdeylaw.com